**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

**គណៈកម្មការមូលបត្រកម្ពុជា**
លេខ: ០០៥/១៨ គ.ម.ក./ប្រ.ក.

# ប្រកាស
# ស្តីពី
# ការផ្តល់ការអនុញ្ញាតដល់ក្រុមហ៊ុនចែកចាយលក់មូលបត្រ និងភ្នាក់ងារចែកចាយលក់មូលបត្រ

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
## និងជាប្រធានគណៈកម្មការមូលបត្រកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៧/០០១ ចុះថ្ងៃទី១០ ខែមករា ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីមូលបត្ររដ្ឋ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០០៧/០២៨ ចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន
- បានឃើញអនុក្រឹត្យលេខ ៩៧ អនក្រ.បក ចុះថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០០៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មការមូលបត្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ៥៤ អនក្រ.បក ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ២០០៩ ស្តីពីការអនុវត្តច្បាប់ស្តីពី

អាសយដ្ឋានបណ្តោះអាសន្ន អគារ ៩៩ ផ្លូវ ៥៩៨ សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ-កម្ពុជា
Temporary Address: #99, Street 598, Sangkat Phnom Penh Thmey, Khan Sen Sok, Phnom Penh, Cambodia
ទូរសព្ទ : ៨៥៥-២៣-៨៨៥-៦១១ ទូរសារ : ៨៥៥-២៣-៨៨៥-៦២២
Phone : 855-23-885-611 Fax : 855-23-885-622
E-mail : info@secc.gov.kh Website : www.secc.gov.kh

ការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន

- បានឃើញប្រកាសលេខ ០០៥/១៥ គ.ម.ក./ប្រក. ចុះថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០១៥ ស្តីពីការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ
- បានឃើញប្រកាសលេខ ០០៩/១៧ គ.ម.ក./ប្រក. ចុះថ្ងៃទី១៧ ខែសីហា ឆ្នាំ២០១៧ ស្តីពីការបោះផ្សាយលក់មូលបត្របំណុលជាសាធារណៈ
- បានឃើញប្រកាសលេខ ០០១/១៨ គ.ម.ក./ប្រក. ចុះថ្ងៃទី២០ ខែមីនា ឆ្នាំ២០១៨ ស្តីពីការផ្តល់អាជ្ញាបណ្ណ និងការគ្រប់គ្រងអាជីវកម្មមូលបត្រ
- យោងតាមការអនុម័តនៃសម័យប្រជុំពេញអង្គរបស់គណៈកម្មការមូលបត្រកម្ពុជា ថ្ងៃទី០៤ ខែកក្កដា ឆ្នាំ២០១៨

## សម្រេច

## ជំពូកទី ១

## បទប្បញ្ញត្តិទូទៅ

### ប្រការ ១.- គោលបំណង

ប្រកាសនេះមានគោលបំណងគ្រប់គ្រងប្រតិបត្តិការអាជីវកម្មចែកចាយលក់មូលបត្រ ក្រុមហ៊ុន និងភ្នាក់ងារដែលទទួលបានការអនុញ្ញាតធ្វើអាជីវកម្មចែកចាយលក់មូលបត្រ ព្រមទាំងបុគ្គលពាក់ព័ន្ធ ឱ្យមានប្រសិទ្ធភាព តម្លាភាព គណនេយ្យភាព សណ្តាប់ធ្នាប់ និងរបៀបរៀបរយ។

### ប្រការ ២.- គោលដៅ

ប្រកាសនេះមានគោលដៅកំណត់ពីលក្ខខណ្ឌ និងនីតិវិធី ក្នុងការផ្តល់ការអនុញ្ញាត និងកំណត់ពីកាតព្វកិច្ចផ្សេងៗរបស់ក្រុមហ៊ុន និងភ្នាក់ងារដែលទទួលបានការអនុញ្ញាតពីគណៈកម្មការមូលបត្រកម្ពុជា (**គ.ម.ក.**) ព្រមទាំងបុគ្គលពាក់ព័ន្ធ។

### ប្រការ ៣.- វិសាលភាព

ប្រកាសនេះមានវិសាលភាពអនុវត្តចំពោះរាល់ប្រតិបត្តិការអាជីវកម្មចែកចាយលក់មូលបត្រ ក្រុមហ៊ុន និងភ្នាក់ងារដែលទទួលបានការអនុញ្ញាតធ្វើអាជីវកម្មចែកចាយលក់មូលបត្រ ព្រមទាំងបុគ្គលពាក់ព័ន្ធនឹងប្រតិបត្តិការនេះនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

### ប្រការ ៤.- និយមន័យ

និយមន័យនៃពាក្យបច្ចេកទេសដែលប្រើប្រាស់នៅក្នុងប្រកាសនេះត្រូវបានកំណត់នៅក្នុងប្រការនេះ និងមាននៅក្នុងសទ្ទានុក្រមដែលជាឧបសម្ព័ន្ធនៃច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន

និងអនុក្រឹត្យស្តីពីការអនុវត្តច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន ប្រកាសស្តីពីការផ្តល់អាជ្ញាបណ្ណ និងការគ្រប់គ្រងអាជីវកម្មមូលបត្រ និងប្រកាសពាក់ព័ន្ធជាធរមាន÷

**ក្រុមហ៊ុនចែកចាយលក់មូលបត្រ** (Securities Selling Firm) ÷ សំដៅដល់នីតិបុគ្គលដែលត្រូវទទួលបានការអនុញ្ញាតពីអគ្គនាយកនៃ **គ.ម.ក.** ដើម្បីធ្វើអាជីវកម្មចែកចាយលក់មូលបត្រដូចកំណត់ក្នុងប្រកាសនេះ។

**ភ្នាក់ងារចែកចាយលក់មូលបត្រ** (Securities Selling Agent) ÷ សំដៅដល់រូបវន្តបុគ្គលដែលត្រូវទទួលបានការអនុញ្ញាតពីអគ្គនាយកនៃ **គ.ម.ក.** ដើម្បីធ្វើប្រតិបត្តិការចែកចាយលក់មូលបត្រដល់សាធារណជនក្នុងនាមជាភ្នាក់ងាររបស់ក្រុមហ៊ុនចែកចាយលក់មូលបត្រ។

**អនុក្រឹត្យ** ÷ សំដៅដល់អនុក្រឹត្យស្តីពីការអនុវត្តច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន។

**អាជីវកម្មចែកចាយលក់មូលបត្រ** (Securities Selling Business) ÷ សំដៅដល់អាជីវកម្មចែកចាយលក់មូលបត្រដល់សាធារណជនតាមការព្រមព្រៀងជាមួយក្រុមហ៊ុនធានាទិញមូលបត្រនៅក្នុងដំណើរការបោះផ្សាយលក់មូលបត្រជាសាធារណៈ។

## ជំពូកទី ២
## ក្រុមហ៊ុនចែកចាយលក់មូលបត្រ

### ប្រការ ៥.- ការអនុញ្ញាតធ្វើជាក្រុមហ៊ុនចែកចាយលក់មូលបត្រ

គ្មានបុគ្គលណាមួយអាចធ្វើអាជីវកម្មជាក្រុមហ៊ុនចែកចាយលក់មូលបត្រ ឬតាំងខ្លួនជាក្រុមហ៊ុនចែក-ចាយលក់មូលបត្របានទេ លើកលែងតែបុគ្គលនោះទទួលបានការអនុញ្ញាតពីអគ្គនាយកនៃ **គ.ម.ក.**។

សុពលភាពនៃការអនុញ្ញាតធ្វើជាក្រុមហ៊ុនចែកចាយលក់មូលបត្រមានរយៈពេលមិនកំណត់។

### ប្រការ ៦.- ការដាក់ពាក្យស្នើសុំការអនុញ្ញាតធ្វើអាជីវកម្មចែកចាយលក់មូលបត្រ

បុគ្គលដែលមានបំណងធ្វើអាជីវកម្មចែកចាយលក់មូលបត្រ ត្រូវដាក់ពាក្យស្នើសុំការអនុញ្ញាតនៅ **គ.ម.ក.** តាមទម្រង់ និងឯកសារភ្ជាប់ដែលកំណត់ដោយអគ្គនាយកនៃ **គ.ម.ក.**។

អគ្គនាយកនៃ **គ.ម.ក.** ត្រូវចាត់ចែងការចុះត្រួតពិនិត្យដល់ទីកន្លែងដើម្បីផ្ទៀងផ្ទាត់ពាក្យស្នើសុំការអនុញ្ញាត។

អគ្គនាយកនៃ **គ.ម.ក.** ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរដល់បុគ្គលដាក់ពាក្យស្នើសុំអំពីការយល់ព្រម ឬបដិសេធផ្តល់ការអនុញ្ញាតដូចមានចែងក្នុងកថាខណ្ឌទី ១ នៃប្រការនេះ ក្នុងរយៈពេលយ៉ាងយូរ ៤៥ (សែសិបប្រាំ) ថ្ងៃ គិតចាប់ពីកាលបរិច្ឆេទដែល **គ.ម.ក.** ទទួលបានពាក្យស្នើសុំ និងឯកសារភ្ជាប់ពេញ-លេញ។

## ប្រការ ៧.- លក្ខខណ្ឌតម្រូវការអនុញ្ញាតក្រុមហ៊ុនចែកចាយលក់មូលបត្រ

បុគ្គលដែលដាក់ពាក្យស្នើសុំការអនុញ្ញាតធ្វើអាជីវកម្មចែកចាយលក់មូលបត្រ ត្រូវបំពេញតាមលក្ខខណ្ឌដូចខាងក្រោម÷

១-ជាក្រុមហ៊ុនដែលបានចុះបញ្ជីពាណិជ្ជកម្មនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

២-ចុះបញ្ជីពន្ធដារអនុលោមតាមច្បាប់ស្ដីពីសារពើពន្ធ និងបទប្បញ្ញត្តិពាក់ព័ន្ធ។

៣-មានមូលធនអប្បបរមាចំនួន ១២០.០០០.០០០ (មួយរយម្ភៃលាន) រៀល ប៉ុន្តែលក្ខខណ្ឌនេះមិនអនុវត្តចំពោះធនាគារ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ក្រុមហ៊ុនធានារ៉ាប់រង ពាណិជ្ជករមូលបត្រ ឈ្មួញជើងសាមូលបត្រ ក្រុមហ៊ុនទីប្រឹក្សាហិរញ្ញវត្ថុ ក្រុមហ៊ុនទីប្រឹក្សាវិនិយោគ ក្រុមហ៊ុនសមភាគីកណ្ដាល ឈ្មួញជើងសាឧបករណ៍និស្សន្ទ ភ្នាក់ងារបញ្ជិកាមូលបត្រ ភ្នាក់ងារចុះបញ្ជីផ្ទេរមូលបត្រ និងភ្នាក់ងារទូទាត់ នៅព្រះរាជាណាចក្រកម្ពុជា។

៤-មានរចនាសម្ព័ន្ធគ្រប់គ្រងដែលកំណត់ច្បាស់លាស់ពីការទទួលខុសត្រូវ និងភារកិច្ច។

៥-មានប្រព័ន្ធ និងគោលនយោបាយពាក់ព័ន្ធនឹងការគ្រប់គ្រងទំនាស់ផលប្រយោជន៍ និងការបំពេញកាតព្វកិច្ចតាមច្បាប់។

៦-មានទីតាំងសមស្រប និងបំពាក់ប្រព័ន្ធ បរិក្ខារ សម្ភារៈជារូបវន្តគ្រប់គ្រាន់សម្រាប់ធ្វើអាជីវកម្ម។

៧-មានភ្នាក់ងារចែកចាយលក់មូលបត្រដែលត្រូវទទួលបានការអនុញ្ញាតពីអគ្គនាយកនៃ **គ.ម.ក.**។ បុគ្គលដាក់ពាក្យស្នើសុំត្រូវមានចំនួនភ្នាក់ងារចែកចាយលក់មូលបត្រឱ្យសមាមាត្រទៅតាមទំហំនៃអាជីវកម្មរបស់ខ្លួន។

៨-លក្ខខណ្ឌផ្សេងទៀតតាមការកំណត់របស់អគ្គនាយកនៃ **គ.ម.ក.**។

## ប្រការ ៨.- ទម្រង់បែបបទ និងឯកសារភ្ជាប់

ឯកសារភ្ជាប់នៃទម្រង់ពាក្យស្នើសុំការអនុញ្ញាតក្រុមហ៊ុនចែកចាយលក់មូលបត្រអាចមានជាអាទិ៍ដូចខាងក្រោម÷

១-វិញ្ញាបនបត្របញ្ជាក់ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មថតចម្លងមានបញ្ជាក់ត្រឹមត្រូវ។

២-អាជ្ញាបណ្ណ ការអនុញ្ញាត ឬការទទួលស្គាល់មានបញ្ជាក់ត្រឹមត្រូវ។

៣-វិញ្ញាបនបត្រចុះបញ្ជីពន្ធដារ និងប័ណ្ណពន្ធប៉ាតង់ថតចម្លងមានបញ្ជាក់ត្រឹមត្រូវ។

៤-លក្ខន្តិកៈក្រុមហ៊ុនថតចម្លងមានបញ្ជាក់ត្រឹមត្រូវ។

៥-កំណត់ហេតុប្រជុំភាគហ៊ុនិក ឬស្ថាបនិក ឬក្រុមប្រឹក្សាភិបាលពាក់ព័ន្ធនឹងការស្នើសុំការអនុញ្ញាត។

៦-លិខិតបញ្ជាក់មូលធនអប្បបរមាដូចមានចែងក្នុងប្រការ ៧ នៃប្រកាសនេះ។

៧-បញ្ជីរាយនាមទីតាំងចែកចាយលក់មូលបត្រដោយបញ្ជាក់ពីអាសយដ្ឋាន និងឈ្មោះបុគ្គលទទួលបន្ទុកនៅទីតាំងចែកចាយលក់មូលបត្រនីមួយៗ។

៨-នីតិវិធីប្រតិបត្តិការពាក់ព័ន្ធនឹងសកម្មភាពអាជីវកម្មចែកចាយលក់មូលបត្រ។

៩-អង្គការលេខដែលបង្ហាញពីរចនាសម្ព័ន្ធរបស់ក្រុមហ៊ុន ដោយបញ្ជាក់ពីតួនាទី និងមុខងាររបស់បុគ្គលទទួលបន្ទុកផ្នែកអាជីវកម្មចែកចាយលក់មូលបត្រ។

១០-បញ្ជីរាយនាមអភិបាលក្រុមហ៊ុន។

១១-ឯកសារផ្សេងទៀតតាមការកំណត់របស់អគ្គនាយកនៃ **គ.ម.ក.**។

## ប្រការ ៩.- ឯកសារបន្ថែម

អគ្គនាយកនៃ **គ.ម.ក.** អាចតម្រូវឱ្យបុគ្គលដាក់ពាក្យស្នើសុំផ្តល់ឯកសារបន្ថែម និងបំភ្លឺនូវចំណុច ឬព័ត៌មានផ្សេងទៀតតាមការចាំបាច់ដើម្បីធានាថាបុគ្គលដាក់ពាក្យស្នើសុំបំពេញបានគ្រប់លក្ខខណ្ឌដែលមានចែងក្នុងប្រកាសនេះ។

## ប្រការ ១០.- ការបដិសេធលើពាក្យស្នើសុំការអនុញ្ញាតក្រុមហ៊ុនចែកចាយលក់មូលបត្រ

អគ្គនាយកនៃ **គ.ម.ក.** អាចបដិសេធលើពាក្យស្នើសុំការអនុញ្ញាតធ្វើអាជីវកម្មចែកចាយលក់មូលបត្រដោយផ្អែកលើមូលហេតុដូចខាងក្រោម÷

១-ការដាក់ពាក្យស្នើសុំមិនបានធ្វើឡើងស្របតាមប្រការ ៦ នៃប្រកាសនេះ។

២-បុគ្គលដាក់ពាក្យស្នើសុំមិនបានបំពេញលក្ខខណ្ឌតម្រូវដូចមានចែងក្នុងប្រការ ៧ និងប្រការ ៨ នៃប្រកាសនេះ។

៣-បុគ្គលដាក់ពាក្យស្នើសុំមិនបានគោរពតាមលក្ខខណ្ឌតម្រូវ ឬសេចក្តីណែនាំផ្សេងទៀតដែលធ្វើឡើងដោយអនុលោមតាមប្រកាសនេះ ពាក់ព័ន្ធនឹងការដាក់ពាក្យស្នើសុំ។

៤-ព័ត៌មាន ឬឯកសារដែលបុគ្គលដាក់ពាក្យស្នើសុំបានដាក់ជូន **គ.ម.ក.** មានលក្ខណៈក្លែងបន្លំ ឬនាំឱ្យយល់ខុស។

៥-បុគ្គលដាក់ពាក្យស្នើសុំស្ថិតក្នុងស្ថានភាពឈានទៅរកការបញ្ឈប់ ឬការរំលាយអាជីវកម្ម។

៦-សេចក្តីសម្រេចរបស់តុលាការដែលតម្រូវឱ្យបុគ្គលដាក់ពាក្យស្នើសុំទូទាត់សងបំណុល មិនត្រូវបានអនុវត្តមួយផ្នែក ឬទាំងស្រុងដោយបុគ្គលដាក់ពាក្យស្នើសុំនោះ។

៧-ស្ថានភាពហិរញ្ញវត្ថុ ឬវិធីធ្វើអាជីវកម្មរបស់បុគ្គលដាក់ពាក្យស្នើសុំមិនទាន់មានលក្ខណៈគ្រប់គ្រាន់។

៨-នៅពេលកើតមានហេតុការណ៍ណាមួយដែលអាច÷

ក-នាំឱ្យបុគ្គលដាក់ពាក្យស្នើសុំ អភិបាល ឬសហកម្មសិទ្ធិករណាម្នាក់ នាយកប្រតិបត្តិ អ្នកគ្រប់គ្រង ឬភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោតច្រើនលើសលប់របស់បុគ្គលដាក់ពាក្យស្នើសុំ មិនអាចធ្វើអាជីវកម្មបានត្រឹមត្រូវ។

ខ-ឆ្លុះបញ្ចាំងពីភាពមិនអាចជឿជាក់បានលើវិធីធ្វើអាជីវកម្មរបស់បុគ្គលដាក់ពាក្យស្នើសុំ។

៩-បុគ្គលដាក់ពាក្យស្នើសុំមាន ឬអាចនឹងមានការពាក់ព័ន្ធនឹងការសម្អាតប្រាក់ និងហិរញ្ញប្បទាន

ភេរវកម្ម ឬការផ្តល់ការអនុញ្ញាតដល់បុគ្គលដាក់ពាក្យស្នើសុំអាចនឹងប៉ះពាល់ផលប្រយោជន៍សាធារណៈ។

**ប្រការ ១១.- ការបែងចែកអាជីវកម្ម**

បុគ្គលដែលទទួលបានការអនុញ្ញាតពីអគ្គនាយកនៃ **គ.ម.ក.** ធ្វើអាជីវកម្មចែកចាយលក់មូលបត្រ ត្រូវធ្វើអាជីវកម្មដាច់ដោយឡែកពីអាជីវកម្មដែលខ្លួនមាន ដោយត្រូវមានទីតាំងអាជីវកម្ម បរិក្ខារ ប្រព័ន្ធព័ត៌មានវិទ្យា ធនធានមនុស្សដាច់ដោយឡែកពីគ្នា និងត្រូវមានរបាំងព័ត៌មាន (Chinese Wall) សមស្រប។

**ប្រការ ១២.- ការផ្អាក ឬការលុបចោលការអនុញ្ញាតក្រុមហ៊ុនចែកចាយលក់មូលបត្រ**

អគ្គនាយកនៃ **គ.ម.ក.** អាចផ្អាក ឬលុបចោលការអនុញ្ញាតក្រុមហ៊ុនចែកចាយលក់មូលបត្រ ក្នុងករណីក្រុមហ៊ុនស្នើសុំផ្អាក ឬឈប់ធ្វើប្រតិបត្តិការអាជីវកម្ម ឬស្ថិតក្នុងស្ថានភាពណាមួយដូចខាងក្រោម÷

១- មិនអាចអនុវត្តសេចក្តីសម្រេចដែលតម្រូវឱ្យសងបំណុលមួយភាគ ឬទាំងស្រុង។

២- កំពុងស្ថិតនៅក្នុងស្ថានភាពបច្ចេកទេស និង/ឬហិរញ្ញវត្ថុទន់ខ្សោយ ឬកំពុងត្រូវរំលាយដោយគ្មានលទ្ធភាពធ្វើអាជីវកម្មបន្ត ឬដោយការវិនិច្ឆ័យរបស់តុលាការ។

៣- មិនអាចបន្តគោរពលក្ខខណ្ឌដូចមានចែងក្នុងប្រការ ៧, ចំណុចទី ៨ ឬទី ៩ នៃប្រការ ១០ នៃប្រកាសនេះ។

**ប្រការ ១៣.- ការបើក ឬបិទទីតាំងចែកចាយលក់មូលបត្រ**

ក្រុមហ៊ុនចែកចាយលក់មូលបត្រត្រូវជូនដំណឹងមក **គ.ម.ក.** ឱ្យបានមួយសប្តាហ៍ មុនដាក់ឱ្យដំណើរការទីតាំងចែកចាយលក់មូលបត្រដើម្បីចែកចាយលក់មូលបត្រ និងត្រូវធានាថាមានភ្នាក់ងារចែកចាយលក់មូលបត្រដែលទទួលបានការអនុញ្ញាតនៅតាមទីតាំងទាំងនោះ។

ក្រុមហ៊ុនចែកចាយលក់មូលត្រត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរមក **គ.ម.ក.** ក្នុងរយៈពេលមួយសប្តាហ៍ មុនបិទទីតាំងចែកចាយលក់មូលបត្រ ដោយត្រូវភ្ជាប់មកជាមួយនូវឯកសារបញ្ជាក់ពីការមិនជាប់ពាក់ព័ន្ធនឹងការចែកចាយលក់មូលបត្រក្នុងដំណើរការបោះផ្សាយលក់មូលបត្រជាសាធារណៈណាមួយ និងឯកសារផ្សេងទៀតដែលកំណត់ដោយអគ្គនាយកនៃ **គ.ម.ក.**។

## ជំពូកទី ៣

## ភ្នាក់ងារចែកចាយលក់មូលបត្រ

**ប្រការ ១៤.- ការអនុញ្ញាតធ្វើជាភ្នាក់ងារចែកចាយលក់មូលបត្រ**

គ្មានបុគ្គលណាមួយអាចធ្វើជាភ្នាក់ងារចែកចាយលក់មូលបត្រ ឬតាំងខ្លួនជាភ្នាក់ងារចែកចាយលក់មូលបត្របានទេ លើកលែងតែបុគ្គលនោះទទួលបានការអនុញ្ញាតពីអគ្គនាយកនៃ **គ.ម.ក.**។

សុពលភាពនៃការអនុញ្ញាតធ្វើជាភ្នាក់ងារចែកចាយលក់មូលបត្រមានរយៈពេលមិនកំណត់។

**ប្រការ ១៥.- ការដាក់ពាក្យស្នើសុំការអនុញ្ញាតធ្វើជាភ្នាក់ងារចែកចាយលក់មូលបត្រ**

បុគ្គលដែលមានបំណងធ្វើជាភ្នាក់ងារចែកចាយលក់មូលបត្រ ត្រូវដាក់ពាក្យស្នើសុំការអនុញ្ញាតនៅ **គ.ម.ក.** តាមទម្រង់ និងឯកសារភ្ជាប់ដែលកំណត់ដោយអគ្គនាយកនៃ **គ.ម.ក.**។

អគ្គនាយកនៃ **គ.ម.ក.** ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរដល់បុគ្គលដាក់ពាក្យស្នើសុំអំពីការយល់ព្រម ឬបដិសេធផ្តល់ការអនុញ្ញាតដូចមានចែងក្នុងកថាខណ្ឌទី ១ នៃប្រការនេះ ក្នុងរយៈពេលយ៉ាងយូរ ៣០(សាមសិប) ថ្ងៃ គិតចាប់ពីកាលបរិច្ឆេទដែល **គ.ម.ក.** ទទួលបានពាក្យស្នើសុំ និងឯកសារភ្ជាប់ពេញលេញ។

**ប្រការ ១៦.- លក្ខខណ្ឌតម្រូវការអនុញ្ញាតធ្វើជាភ្នាក់ងារចែកចាយលក់មូលបត្រ**

បុគ្គលដាក់ពាក្យស្នើសុំការអនុញ្ញាតធ្វើជាភ្នាក់ងារចែកចាយលក់មូលបត្រត្រូវបំពេញតាមលក្ខខណ្ឌដូចខាងក្រោម÷

១- មានលក្ខណសម្បត្តិ និងអត្តចរិតល្អ។

២- ជាសមត្ថជន និងមានលំនៅឋានក្នុងព្រះរាជាណាចក្រកម្ពុជា។

៣- បំពេញលក្ខខណ្ឌយ៉ាងហោចណាស់មួយក្នុងចំណោមលក្ខខណ្ឌដូចខាងក្រោម÷

ក- មានសញ្ញាបត្រយ៉ាងតិចកម្រិតឧត្តមសិក្សាពាក់ព័ន្ធនឹងវិស័យហិរញ្ញវត្ថុ មូលបត្រ សេដ្ឋកិច្ច គណនេយ្យ ឬសញ្ញាបត្រផ្សេងទៀតដែលមានតម្លៃប្រហាក់ប្រហែល។

ខ- មានវិញ្ញាបនបត្របញ្ជាក់ការចូលរួមវគ្គបណ្តុះបណ្តាលពាក់ព័ន្ធនឹងវិស័យមូលបត្រ ឬហិរញ្ញវត្ថុ និងមានបទពិសោធន៍ការងារយ៉ាងតិចមួយឆ្នាំ នៅក្នុងទីផ្សារហិរញ្ញវត្ថុ។

៤- ចូលរួមការបណ្តុះបណ្តាល និងការប្រឡងដែលរៀបចំដោយ **គ.ម.ក.** ឬស្ថាប័នបណ្តុះបណ្តាលដែលទទួលបានសិទ្ធិពី **គ.ម.ក.** ហើយលទ្ធផលប្រឡងមានសុពលភាព ២ (ពីរ) ឆ្នាំ គិតចាប់ពីកាលបរិច្ឆេទដែល **គ.ម.ក.** ប្រកាសលទ្ធផលប្រឡង។ មុនពេលលទ្ធផលប្រឡង ឬលទ្ធផលនៃការចូលរួមកម្មវិធីអប់រំវិជ្ជាជីវៈបន្តអស់សុពលភាព ភ្នាក់ងារចែកចាយលក់មូលបត្រត្រូវចូលរួមកម្មវិធីអប់រំវិជ្ជាជីវៈបន្តដែលរៀបចំដោយ **គ.ម.ក.** ឬស្ថាប័នបណ្តុះបណ្តាលដែលទទួលបានសិទ្ធិពី **គ.ម.ក.**។

៥- មានលិខិតបញ្ជាក់យល់ព្រមពីក្រុមហ៊ុនចែកចាយលក់មូលបត្រឱ្យធ្វើជាភ្នាក់ងារចែកចាយលក់មូលបត្រ។

៦- មិនធ្លាប់ប្រព្រឹត្តអ្វីដែលប៉ះពាល់ដល់ប្រយោជន៍សាធារណៈធ្ងន់ធ្ងរ។

**ប្រការ ១៧.- ការបដិសេធលើពាក្យស្នើសុំការអនុញ្ញាតធ្វើជាភ្នាក់ងារចែកចាយលក់មូលបត្រ**

អគ្គនាយកនៃ **គ.ម.ក.** អាចបដិសេធលើពាក្យស្នើសុំការអនុញ្ញាតធ្វើជាភ្នាក់ងារចែកចាយលក់មូលបត្រដោយផ្អែកលើមូលហេតុដូចខាងក្រោម÷

១- ការដាក់ពាក្យស្នើសុំមិនបានធ្វើឡើងស្របតាមប្រការ ១៥ នៃប្រកាសនេះ។

២- បុគ្គលដាក់ពាក្យស្នើសុំមិនបានបំពេញលក្ខខណ្ឌតម្រូវដូចមានចែងក្នុងប្រការ ១៦ នៃប្រកាសនេះ។

៣- បុគ្គលដាក់ពាក្យស្នើសុំមិនបានគោរពតាមលក្ខខណ្ឌតម្រូវ ឬសេចក្តីណែនាំផ្សេងទៀតដែលធ្វើឡើងដោយអនុលោមតាមប្រកាសនេះពាក់ព័ន្ធនឹងការដាក់ពាក្យស្នើសុំ។

៤- ព័ត៌មាន ឬឯកសារដែលបុគ្គលដាក់ពាក្យស្នើសុំបានដាក់ជូន **គ.ម.ក.** មានលក្ខណៈក្លែងបន្លំ ឬនាំឱ្យយល់ខុស។

៥- សេចក្តីសម្រេចរបស់តុលាការដែលតម្រូវឱ្យបុគ្គលដាក់ពាក្យស្នើសុំទូទាត់សងបំណុល មិនត្រូវបានអនុវត្តមួយផ្នែក ឬទាំងស្រុងដោយបុគ្គលដាក់ពាក្យស្នើសុំនោះ។

៦- បុគ្គលដាក់ពាក្យស្នើសុំមាន ឬអាចនឹងមានការពាក់ព័ន្ធនឹងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម ឬការផ្តល់ការអនុញ្ញាតដល់បុគ្គលដាក់ពាក្យស្នើសុំអាចនឹងប៉ះពាល់ផលប្រយោជន៍សាធារណៈ។

## ប្រការ ១៨.- ការផ្អាក ឬការលុបចោលការអនុញ្ញាតរបស់ភ្នាក់ងារចែកចាយលក់មូលបត្រ

អគ្គនាយកនៃ **គ.ម.ក.** អាចផ្អាក ឬលុបចោលការអនុញ្ញាតភ្នាក់ងារចែកចាយលក់មូលបត្រ ក្នុងករណីភ្នាក់ងារចែកចាយលក់មូលបត្រស្ថិតក្នុងស្ថានភាពណាមួយដូចខាងក្រោម÷

១- មិនអាចអនុវត្តសេចក្តីសម្រេចដែលតម្រូវឱ្យសងបំណុលមួយភាគ ឬទាំងស្រុង។

២- ក្លាយជាអសមត្ថជន។

៣- លាឈប់ ឬផ្លាស់ប្តូរការងារ។

៤- មិនអាចបន្តគោរពលក្ខខណ្ឌដូចមានចែងក្នុងប្រការ ១៦, ចំណុចទី ៣, ទី ៤, ទី ៥ ឬទី ៦ នៃប្រការ ១៧ នៃប្រកាសនេះ។

# ជំពូកទី ៤

# បទប្បញ្ញត្តិផ្សេងៗ

## ប្រការ ១៩.- ការកែប្រែឯកសារ ឬព័ត៌មាន

ក្រុមហ៊ុនចែកចាយលក់មូលបត្រ ភ្នាក់ងារចែកចាយលក់មូលបត្រ ឬបុគ្គលដាក់ពាក្យស្នើសុំ ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរជាបន្ទាន់មក **គ.ម.ក.** ក្នុងករណីមានការកែប្រែឯកសារ ឬព័ត៌មានពាក់ព័ន្ធនឹងពាក្យស្នើសុំការអនុញ្ញាត។

## ប្រការ ២០.- ការលាឈប់ ការបញ្ចប់តួនាទី ឬការផ្លាស់ប្តូរមុខងាររបស់ភ្នាក់ងារចែកចាយលក់មូលបត្រ

ក្រុមហ៊ុនចែកចាយលក់មូលបត្រត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរមក **គ.ម.ក.** អំពីការលាឈប់ការបញ្ចប់តួនាទី ឬការផ្លាស់ប្តូរមុខងាររបស់ភ្នាក់ងារចែកចាយលក់មូលបត្ររបស់ខ្លួន ក្នុងរយៈពេល ១៥

(ដប់ប្រាំ) ថ្ងៃ បន្ទាប់ពីកាលបរិច្ឆេទទទួលបានលិខិតលាឈប់ពីការងារ ការសម្រេចបញ្ចប់តួនាទី ឬការផ្លាស់ប្ដូរមុខងាររបស់ភ្នាក់ងារនោះ។

ក្រុមហ៊ុនចែកចាយលក់មូលបត្រត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរមក **គ.ម.ក.** ក្នុងរយៈពេល ២(ពីរ) ថ្ងៃ មុនផ្លាស់ប្ដូរភ្នាក់ងារចែកចាយលក់មូលបត្រពីទីតាំងចែកចាយលក់មូលបត្រមួយទៅទីតាំងចែកចាយលក់មូលបត្រផ្សេងទៀត។

## ប្រការ ២១.- កាតព្វកិច្ចផ្ដល់របាយការណ៍

ក្រុមហ៊ុនចែកចាយលក់មូលបត្រមានកាតព្វកិច្ចផ្ដល់របាយការណ៍សមាជិក និង/ឬ របាយការណ៍ផ្សេងទៀតជូន **គ.ម.ក.** តាមការកំណត់របស់អគ្គនាយកនៃ **គ.ម.ក.**។

## ប្រការ ២២.- ការផ្លាស់ប្ដូរ ឬការកែប្រែព័ត៌មានពាក់ព័ន្ធនឹងលក្ខខណ្ឌនៃការអនុញ្ញាត

មុននឹងធ្វើការផ្លាស់ប្ដូរ ឬកែប្រែព័ត៌មានពាក់ព័ន្ធនឹងលក្ខខណ្ឌនៃការអនុញ្ញាត ក្រុមហ៊ុនចែកចាយលក់មូលបត្រត្រូវស្នើសុំការអនុញ្ញាតពីអគ្គនាយកនៃ **គ.ម.ក.** និងត្រូវបង់សោហ៊ុយសិក្សាសំណុំលិខិតជាសាច់ប្រាក់ចំនួន ១០០.០០០(មួយរយពាន់) រៀល សម្រាប់ការផ្លាស់ប្ដូរ ឬកែប្រែនីមួយៗ នៅពេលដាក់ពាក្យស្នើសុំ។

## ប្រការ ២៣.- ការផ្ដល់មុខងារចែកចាយលក់មូលបត្រ

ករណីក្រុមហ៊ុនធានាទិញមូលបត្រមានបំណងផ្ដល់មុខងារចែកចាយលក់មូលបត្រនៅក្នុងដំណាក់កាលបោះផ្សាយលក់មូលបត្រជាសាធារណៈទៅឲ្យបុគ្គលផ្សេង ក្រុមហ៊ុនធានាទិញមូលបត្រត្រូវជ្រើសរើសក្រុមហ៊ុនចែកចាយលក់មូលបត្រដែលទទួលបានការអនុញ្ញាត និង/ឬក្រុមហ៊ុនធានាទិញមូលបត្រដែលទទួលបានអាជ្ញាបណ្ណពីអគ្គនាយកនៃ **គ.ម.ក.** និងត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរមក **គ.ម.ក.** ដោយភ្ជាប់មកជាមួយនូវកិច្ចព្រមព្រៀងរវាងក្រុមហ៊ុនធានាទិញមូលបត្រ និងក្រុមហ៊ុនចែកចាយលក់មូលបត្រ និង/ឬក្រុមហ៊ុនធានាទិញមូលបត្រផ្សេងទៀត ក្នុងរយៈពេល ៧(ប្រាំពីរ) ថ្ងៃនៃថ្ងៃធ្វើការ បន្ទាប់ពីកាលបរិច្ឆេទចុះកិច្ចព្រមព្រៀង។

ក្រុមហ៊ុនធានាទិញមូលបត្រដែលបានផ្ដល់មុខងារឲ្យក្រុមហ៊ុនចែកចាយលក់មូលបត្រ និង/ឬក្រុមហ៊ុនធានាទិញមូលបត្រផ្សេងទៀតធ្វើការចែកចាយលក់មូលបត្រជំនួស ត្រូវបំពេញរាល់កាតព្វកិច្ច និងទំនួលខុសត្រូវដូចមានចែងក្នុងច្បាប់ស្ដីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន អនុក្រឹត្យ ប្រកាសនេះ និងបទប្បញ្ញត្តិផ្សេងទៀតជាធរមាន។

## ប្រការ ២៤.- ការទទួលខុសត្រូវចំពោះការធ្វើប្រតិបត្តិការចែកចាយលក់មូលបត្រ

ក្រុមហ៊ុនចែកចាយលក់មូលបត្រដែលធ្វើអាជីវកម្មចែកចាយលក់មូលបត្រត្រូវ÷

១- ធានាថាសេវាដែលផ្ដល់ដោយភ្នាក់ងារចែកចាយលក់មូលបត្ររបស់ខ្លួនមានសុវត្ថិភាព និងមិនប៉ះពាល់ដល់ផលប្រយោជន៍របស់អតិថិជន។

២- ទទួលខុសត្រូវទាំងស្រុងចំពោះរាល់សកម្មភាពរបស់ភ្នាក់ងារចែកចាយលក់មូលបត្ររបស់ខ្លួន។

៣- ផ្តល់ជូន **គ.ម.ក.** នូវបញ្ជីឈ្មោះភ្នាក់ងារចែកចាយលក់មូលបត្ររបស់ខ្លួន ដោយបញ្ជាក់ឈ្មោះ និងអាសយដ្ឋាននៃទីតាំងដែលភ្នាក់ងារចែកចាយលក់មូលបត្រទាំងនោះធ្វើប្រតិបត្តិការចែកចាយលក់មូលបត្រ។

**ប្រការ ២៥.- ការចុះត្រួតពិនិត្យដល់ទីកន្លែង**

អគ្គនាយកនៃ **គ.ម.ក.** អាចចាត់មន្ត្រីជំនាញឲ្យចុះត្រួតពិនិត្យដល់ទីកន្លែងក្រុមហ៊ុនចែកចាយលក់មូលបត្រ ដើម្បីពិនិត្យការអនុវត្តតាមលក្ខខណ្ឌនៃការអនុញ្ញាត ប្រតិបត្តិការអាជីវកម្មរបស់ក្រុមហ៊ុន សកម្មភាពរបស់ភ្នាក់ងារចែកចាយលក់មូលបត្រ អនុលោមតាមច្បាប់ និងបទប្បញ្ញត្តិជាធរមាន។

ក្រុមហ៊ុនចែកចាយលក់មូលបត្រត្រូវផ្តល់កិច្ចសហការ ឯកសារ និង/ឬព័ត៌មាន ដល់មន្ត្រីនៃ **គ.ម.ក.** ដែលត្រូវចាត់តាំងដោយអគ្គនាយកនៃ **គ.ម.ក.** ដើម្បីចុះត្រួតពិនិត្យដល់ទីកន្លែង។

## ជំពូកទី ៥

## កម្រៃ

**ប្រការ ២៦.- ថ្លៃពាក្យស្នើសុំ សោហ៊ុយសិក្សាសំណុំលិខិត និងថ្លៃការអនុញ្ញាត**

បុគ្គលដាក់ពាក្យស្នើសុំត្រូវបង់ថ្លៃពាក្យស្នើសុំ សោហ៊ុយសិក្សាសំណុំលិខិត និងថ្លៃការអនុញ្ញាតទៅតាមកម្រៃដូចខាងក្រោម÷

១- ចំពោះការស្នើសុំការអនុញ្ញាតធ្វើអាជីវកម្មចែកចាយលក់មូលបត្រ

- ថ្លៃពាក្យស្នើសុំការអនុញ្ញាតចំនួន ២០.០០០ (ម្ភៃពាន់) រៀល ក្នុងមួយច្បាប់
- សោហ៊ុយសិក្សាសំណុំលិខិតចំនួន ៦០០.០០០ (ប្រាំមួយរយពាន់) រៀល
- ថ្លៃការអនុញ្ញាតប្រចាំឆ្នាំចំនួន ១.០០០.០០០ (មួយលាន) រៀល ដោយគិតចាប់ពីកាលបរិច្ឆេទនៃការអនុញ្ញាត។ សម្រាប់ឆ្នាំបន្ទាប់ បុគ្គលដាក់ពាក្យស្នើសុំត្រូវបង់ថ្លៃការអនុញ្ញាតប្រចាំឆ្នាំយ៉ាងយូរ ៣០ (សាមសិប) ថ្ងៃ មុនថ្ងៃខែដែលទទួលបានការអនុញ្ញាត។

២- ចំពោះការស្នើសុំការអនុញ្ញាតធ្វើជាភ្នាក់ងារចែកចាយលក់មូលបត្រ

- ថ្លៃពាក្យស្នើសុំការអនុញ្ញាតចំនួន ២០.០០០ (ម្ភៃពាន់) រៀល ក្នុងមួយច្បាប់
- សោហ៊ុយសិក្សាសំណុំលិខិតចំនួន ៤០.០០០ (សែសិបពាន់) រៀល
- ថ្លៃការអនុញ្ញាតប្រចាំឆ្នាំចំនួន ១០០.០០០ (មួយរយពាន់) រៀល ដោយគិតចាប់ពីកាលបរិច្ឆេទនៃការអនុញ្ញាត។ សម្រាប់ឆ្នាំបន្ទាប់ បុគ្គលដាក់ពាក្យស្នើសុំត្រូវបង់ថ្លៃការអនុញ្ញាតប្រចាំឆ្នាំយ៉ាងយូរ ៣០ (សាមសិប) ថ្ងៃ មុនថ្ងៃខែដែលទទួលបានការអនុញ្ញាត។

បុគ្គលដាក់ពាក្យស្នើសុំត្រូវបង់ថ្លៃពាក្យស្នើសុំ និងសោហ៊ុយសិក្សាសំណុំលិខិត នៅពេលដាក់ពាក្យ

ស្នើសុំនៅ **គ.ម.ក.**។

ថ្លៃពាក្យស្នើសុំ និងសោហ៊ុយសិក្សាសំណុំលិខិតអនុលោមតាមប្រការនេះ មិនត្រូវបានប្រគល់ឱ្យបុគ្គលដាក់ពាក្យស្នើសុំវិញឡើយ ទោះបីការស្នើសុំការអនុញ្ញាតត្រូវបានបដិសេធក៏ដោយ។

## ជំពូកទី ៦
## ទោសប្បញ្ញត្តិ

### ប្រការ ២៧.- ពិន័យអន្តរការណ៍

អគ្គនាយកនៃ **គ.ម.ក.** អាចចាត់វិធានការពិន័យអន្តរការណ៍ជាសាច់ប្រាក់ដូចខាងក្រោម÷

១- មិនលើសពី ៥០.០០០.០០០ (ហាសិបលាន) រៀលចំពោះភ្នាក់ងារចែកចាយលក់មូលបត្រដែលប្រព្រឹត្តល្មើសនឹងប្រការ ១៦, ចំណុចទី ២ នៃប្រការ ២៦ នៃប្រកាសនេះ ឬមិនគោរពតាមការណែនាំរបស់អគ្គនាយកនៃ **គ.ម.ក.**។

២- មិនលើសពី ២០០.០០០.០០០ (ពីររយលាន) រៀលចំពោះក្រុមហ៊ុនចែកចាយលក់មូលបត្រដែលប្រព្រឹត្តល្មើសនឹងប្រការ ៧, ប្រការ ១១, ប្រការ ១៣, ប្រការ ២០, ប្រការ ២១, ប្រការ ២២, ប្រការ ២៤, ប្រការ ២៥, ចំណុចទី ១ នៃប្រការ ២៦ នៃប្រកាសនេះ ឬមិនគោរពតាមការណែនាំរបស់អគ្គនាយកនៃ **គ.ម.ក.**។

### ប្រការ ២៨.- ទណ្ឌកម្មរដ្ឋបាល

ករណីក្រុមហ៊ុនចែកចាយលក់មូលបត្រប្រព្រឹត្តល្មើសនឹងប្រការ ៧, ប្រការ ១១, ប្រការ ១៣, ប្រការ ២០, ប្រការ ២១, ប្រការ ២២, ប្រការ ២៤, ប្រការ ២៥, ចំណុចទី ១ នៃប្រការ ២៦ នៃប្រកាសនេះ ឬមិនគោរពតាមការណែនាំរបស់អគ្គនាយកនៃ **គ.ម.ក.** និងភ្នាក់ងារចែកចាយលក់មូលបត្រប្រព្រឹត្តល្មើសនឹងប្រការ ១៦, ចំណុចទី ២ នៃប្រការ ២៦ នៃប្រកាសនេះ ឬមិនគោរពតាមការណែនាំរបស់អគ្គនាយកនៃ **គ.ម.ក.** អគ្គនាយកនៃ **គ.ម.ក.** មានសិទ្ធិចាត់វិធានការពិន័យអន្តរការណ៍ និង/ឬទណ្ឌកម្មរដ្ឋបាលណាមួយដូចខាងក្រោម÷

១- ព្រមាន។

២- ដឹកនាំកែតម្រង់។

៣- ដាក់កំហិតលើការអនុញ្ញាត។

៤- ព្យួរការអនុញ្ញាត។

៥- ដកហូតការអនុញ្ញាត។

## ជំពូកទី ៧
## អវសានប្បញ្ញត្តិ

**ប្រការ ២៩.- គោលការណ៍ណែនាំផ្សេងៗ**

អគ្គនាយកនៃ **គ.ម.ក.** អាចចេញគោលការណ៍ណែនាំអនុលោមតាមច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន អនុក្រឹត្យ និងប្រកាសនេះ ដើម្បីសម្រួលដល់ការយល់ដឹង និងការអនុវត្ត។

**ប្រការ ៣០.- បដិនិយកម្ម**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនិងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ ៣១.- ការអនុវត្ត**

អគ្គនាយកនៃ **គ.ម.ក.** ប្រធាននាយកដ្ឋានត្រួតពិនិត្យអន្តរការីមូលបត្រ ប្រធាននាយកដ្ឋានកិច្ចការគតិយុត្ត គ្រប់ប្រធាននាយកដ្ឋាន-អង្គភាពដែលស្ថិតនៅចំណុះឲ្យ **គ.ម.ក.** និងបុគ្គលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃអង្គារ ១៣ រោច ខែបឋមាសាឍ ឆ្នាំច សំរឹទ្ធិស័ក ព.ស. ២៥៦២

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១០ ខែកក្កដា ឆ្នាំ២០១៨

**ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**និងជាប្រធានគណៈកម្មការមូលបត្រកម្ពុជា**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**ចម្លងជូន ÷**

-ទីស្តីការគណៈរដ្ឋមន្ត្រី

-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

-ក្រសួងពាណិជ្ជកម្ម

-ក្រសួងយុត្តិធម៌

-ធនាគារជាតិនៃកម្ពុជា

-អគ្គលេខាធិការរាជរដ្ឋាភិបាល

-ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន**
នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

-ខុទ្ទកាល័យឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
"ដើម្បីជូនជ្រាប"

-ដូចប្រការ ៣១
"ដើម្បីអនុវត្ត"

-រាជកិច្ច

-ឯកសារ-កាលប្បវត្តិ